# សាធារណរដ្ឋខ្មែរ

លោក ស៊ីសុវត្ថិ សិរិមតៈ

ផ្ញើលិខិតចំហ ចំពោះស្តេចសីហនុ

នាថ្ងៃទី ២៧ សីហា ១៩៧៣

# OPEN LETTER TO PRINCE SIHANOUK

## BY SISOWATH SIRIK MATAK

AUGUST 27, 1973

# លោក ស៊ីសុវត្ថិ សិរិមតៈ ផ្ញើលិខិតចំហ

## ចំពោះ

# ស្តេចសីហនុ

ទ្រង់ប្អូន !

ប្រសិនបើទ្រង់ប្អូន ធ្វើការត្រិះរិះពិចារណាដោយសុទ្ធចិត្តក្នុងសតិសម្បជញ្ញៈរបស់ប្អូននោះ ប្អូននឹងយល់ឃើញថា គឺរូបប្អូននេះហើយដែលជាប្រភព នៃសង្គ្រាមឃ្លានពានសព្វថ្ងៃដែលធ្វើឲ្យប្រទេសជាតិរបស់ខ្លួនទទួលនូវការខូចខាត និង ការបាត់បង់ជីវិតយ៉ាងច្រើន ។ ប្រសិនបើទ្រង់ប្អូនទទួលយកដោយសេចក្តីថ្លៃថ្នូរ និងប្រកបដោយការបរិច្ចាគ នូវការវិនិច្ឆ័យរបស់អ្នកតំណាងពេញលក្ខណៈច្បាប់នៃប្រជាពលរដ្ឋ ដែលបានប្រកាសទម្លាក់ប្អូនឯងជាឯកច្ឆន្ទ ដូចដែលប្រមុខរដ្ឋជាច្រើនដទៃទៀត ដែលត្រូវគេទម្លាក់ពីអំណាចនៅពេលមុនឬក្រោយប្អូនឯងក្នុងលក្ខណៈដូចប្អូនឯងដែរនោះ នោះប្អូនប្រាកដជាអាចបញ្ចៀសមិនឲ្យប្រជាពលរដ្ឋយើងទទួលនូវសេចក្តីវេទនាទុក្ខវេទនាឡើយ ។

ផ្ទុយទៅវិញ ប្អូន មិនបានធ្វើដូច្នោះទេ ហើយបែរទៅជាក្លែងបង្កើតរដ្ឋាភិបាលភៀសខ្លួនមួយ ដែលសមាជិកនានាបិតនៅអារាត់អារាយតាមរដ្ឋធានីនៃប្រទេសនានា ហើយដែលគ្មានទីស្នាក់ការច្បាស់លាស់នៅក្នុងទឹកដីខ្មែរ ។ អាក្រក់ជាងនេះទៅទៀត គឺប្អូនបានអំពាវនាវហៅកងទ័ពយៀកណាមខាងជើងនិងយៀកកុង

ដែលរង់ចាំតែសញ្ញា ដើម្បីចូលមកឈ្លានពានយ៉ាងចំហប្រឆាំងនឹងប្រទេសខ្មែរ ដោយយកលេសថា ការវាតត្បាតដោយស្វាត់ស្ងៀមនិងកាន់តែខ្លាំងឡើងបន្តិចម្តង ៗ ដែលពួកនេះបានចាប់ផ្តើមធ្វើឡើងនៅប្រទេសខ្មែរ តាំងពី ៥ ឆ្នាំមកហើយនោះ គឺជាការត្រឹមត្រូវ ដោយសំអាងថាប្អូនឯងនេះបានសុំឲ្យពួកវា មកធ្វើអន្តរាគមន៍ ។

ប្អូនអាចយល់បានថា ប្រសិនបើនៅពេលនេះ មិត្តភក្តិយៀកណាមខាងជើង-យៀកកុងរបស់ប្អូនឯង បានបង្កើត - រៀបចំនិងគាំទ្រពេញកម្លាំងចលនាខ្មែរក្រហមនៅក្នុងស្រុកខ្មែរនោះ គឺប្រាកដជាមិនមែនធ្វើឡើងដើម្បីផ្គាប់ចិត្តប្អូន ឬ ក្នុងផលប្រយោជន៍របស់ប្អូនឡើយ ។ ពួកវាប៉ិនប្រសប់ណាស់ហើយជាមនុស្សប្រកបដោយគ្រោះថ្នាក់ផង ដោយពួកវាមានទីដៅយ៉ាងវែងឆ្ងាយឆ្ពោះទៅរកការធ្វើឲ្យប្រទេសយើងក្លាយទៅជាអាណាចយៀកណាមខាងជើង ។

លុះដល់ទីបំផុតទៅ គឺប្អូននេះហើយដែលត្រូវចាញ់បោកយៀកណាមខាងជើងយៀកកុង ហើយការដែលប្អូនយល់ច្រឡំយ៉ាងដូច្នេះ ធ្វើឲ្យកើតសង្គ្រាមយ៉ាងសាហាវមួយដល់ប្រទេសប្អូន ហើយដោយកំហុសរបស់ប្អូនឯង ប្រទេសខ្មែរអាចនឹងត្រូវគេលុបចេញពីផែនទីសាកលលោកផង ។

បងយល់ឃើញថា មិនទាន់ជ្រុលពេលវេលាទេចំពោះប្អូន ក្នុងការធ្វើការពិចារណារិះគន់ខ្លួនឯង និង ដើម្បីកែខ្លួន ។ ឯង ហើយបងសង្ឃឹមថា បងធ្វើសេចក្តីអំពាវនាវដល់ប្អូនឯងនេះ គឺដើម្បីធ្វើវិភាគទានមួយក្នុងការស្រោចស្រង់ជាតិ ។

ការទាំងនោះគឺសុទ្ធតែធ្វើកើតទាំងអស់ ប្រសិនបើព្រកបដោយសតិសម្បជញ្ញៈ ប្អូនទទួលស្គាល់ថា គឺប្អូនឯងនេះហើយដែលជាអ្នកទទួលខុសត្រូវ ក្នុងការធ្វើឲ្យរលាយសាបសូន្យនៃរបបរាជនិយមខ្មែរ និង ធ្វើឲ្យមានសេចក្តីទុក្ខវេទនាដល់ប្រជារាស្ត្រក្នុងពេលបច្ចុប្បន្ន ព្រមទាំងការបំផ្លាញនយោបាយ អព្យាក្រឹតនៅក្នុងសង្គ្រាមនៅឥណ្ឌូចិន និងនៅចំពោះមុខប្រទេសដែលមិនចូលរួមក្នុងបក្សសម្ព័ន្ធណាផង ។

នៅពេលដែលព្រះករុណាព្រះនរោត្តមសុរាម្រឹត ដែលត្រូវជាឪពុករបស់ប្អូន និងត្រូវជាមារបស់បងត្រូវបាត់បង់ទៅ ហើយដែលមិនបានតែងតាំងមហាក្សត្រថ្មីមួយ ដើម្បីគ្រងរាជ្យបន្តទៀតនោះ ប្អូនក៏មិនអាចឡើងគ្រងរាជ្យបានដែរ ដោយនៅក្នុងឆ្នាំ ១៩៥៥ គឺប្រាំឆ្នាំមុន ប្អូនបានធ្វើសេចក្តីសម្រេចចិត្តដ៏អាក្រក់មួយក្នុងការដាក់រាជ្យ ហើយសច្ចាជាឧឡារិកថា នឹងមិនឡើងកាន់អំណាចវិញឡើយ ។

ស្របតាមមាត្រា ៣០ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវតែប្រជុំក្នុងរវាង ៣ ថ្ងៃ ក្រោយព្រឹត្តិការណ៍ដែលធ្វើឲ្យរាជសម្បត្តិទំនេរ ដើម្បីចាត់តាំងព្រះមហាក្សត្រអង្គថ្មីព្រមទាំងរាជានុសិទ្ធិ បើព្រះមហាក្សត្រអង្គថ្មីឋិតនៅក្នុងអនីតិភាព » ។

នៅពេលនោះ ទ្រង់ប្អូននៅមានប្រជប្រិយភាពនៅឡើយ ហើយប្រជារាស្ត្រក៏នៅស្រឡាញ់ប្អូនដែរ ។ ប្អូនអាចឡើងគ្រងរាជ្យសម្បត្តិបន្តពីឪពុកប្អូនបានយ៉ាងស្រួល ប្រសិនបើមាត្រា ៣០ ស្តីនៃរដ្ឋធម្មនុញ្ញដែលប្អូនបានធ្វើឲ្យគេអនុម័តយកតាមគោលគំនិតរបស់ប្អូនឯងនោះ មិនបានហាមឃាត់ប្អូនទេ ។

ក្នុងករណីនេះ មាត្រា ៣០ ស្ដីនបានចែងថា « ក្នុងករណីដែលកាលៈទេសៈពុំអាចឲ្យចាត់តាំងបាននូវព្រះមហាក្សត្រអង្គថ្មី ក្រុមប្រឹក្សារាជ្យសម្បត្តិក្នុងរយៈវេលាដដែល ដូចមានចែងក្នុងមាត្រាខាងលើត្រូវការចាត់តាំងក្រុមប្រឹក្សារាជានុសិទ្ធិមួយ ដែលត្រូវបំពេញជាបណ្ដោះអាសន្ននូវព្រះរាជ្យបុព្វសិទ្ធិក្នុងលក្ខខ័ណ្ឌទាំងឡាយ ដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញនេះ » ។

ប៉ុន្ដែ នៅពេលនោះ « យុវជនរាជសង្គមនិយមខ្មែរ » ដែលជាអង្គការមួយក្នុងបណ្ដាអង្គការជាច្រើនទៀតដែលប្អូនបានបង្កើតនោះ បានរៀបចំធ្វើបាតុកម្មតាមបញ្ជារបស់ប្អូន ដើម្បីទាមទារឲ្យប្អូនឯងឡើងកាន់នាទីជា «ប្រមុខរដ្ឋ» ដែលរដ្ឋធម្មនុញ្ញមិនបានព្រាងទុកទាល់តែសោះ ។ ដោយសំអាងលើលេសនេះ ប្អូនបានធ្វើសារមួយទៅកាន់ប្រជាជាតិ សុំឲ្យស្ថាប័នទាំងឡាយនៃប្រទេសធ្វើការកែប្រែរដ្ឋធម្មនុញ្ញដោយបង្កើតមុខតំណែង « ប្រមុខរដ្ឋ » ។

នៅសម័យនោះ ចំណង់ប្អូន គឺជាបញ្ជា ។ សភាទាំងពីរក៏បានរួមប្រជុំដើម្បីអនុម័តមាត្រាបន្ថែមមួយក្នុងគោលបំណងបំពេញចិត្តប្អូន ហើយជាបន្ទាប់មកគឺនៅថ្ងៃ ១៥ មិថុនា ១៩៦០ ក៏បានតែងតាំងប្អូន ជា « ប្រមុខរដ្ឋ » ដែលជាងារមួយដែលប្អូនបានកាន់កាប់ក្នុងរយៈពេលដ៏យូរ និងខុសច្បាប់ផង រហូតដល់ថ្ងៃដែលសភាទាំងពីរបានទម្លាក់ប្អូនទៅនៅខែមិនា ឆ្នាំ ១៩៧០ ។ ចាប់ពីពេលនោះមក គេមើលឃើញច្បាស់ទាំងអស់គ្នាថា ក្នុងការប្រើអំណាចផ្ទាល់ខ្លួនដោយរំលោភ ប្អូនឯងបានសម្លាប់របបរាជនិយមខ្មែរដោយដៃប្អូនឯងផ្ទាល់ ។

បងត្រូវទទួលស្គាល់លក្ខណៈមួយដ៏ប្រសើររបស់ប្អូន គឺប្អូនជាមនុស្សមានចរិតនឹងនល្អណាស់ តែនឹងនក្នុងក្តីសារ៉ា ។ ពួកមនុស្សដែលប្អូនឯងស្មានថា សព្វថ្ងៃនេះជាមិត្តភក្តិរបស់ប្អូន គឺពួកមនុស្សនោះហើយដែលធ្វើឲ្យប្អូនធ្លាក់ខ្លួនធ្វើឲ្យប្រជារាស្ត្រស្អប់គ្រប់ ៗ គ្នា ។

ហេតុដូច្នេះហើយ បានជានៅក្នុងវិចារណកថាមួយ នៅក្នុងទស្សនាវដ្តី «ឡឺសង្គម» ខែកញ្ញា ១៩៦៦ ប្អូនបានបរិហារថា ពួកខ្មែរក្រហមគឺសុទ្ធតែជាពួកក្បត់ជាតិ គឺ «មិនមែនជាខ្មែរ» ដែលបានដាក់ប្រទេសខ្លួនចាប់តាំងពីសម័យក្រោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ ១៩៥៤ មកឲ្យនៅក្រោមអាណានិគមនិយម សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។

ឆ្នាំជាបន្ទាប់មក ប្អូនឯងបានចោទប្រកាន់របបគ្រប់គ្រងក្រុងប៉េកាំង ជាសាធារណៈហើយសព្វថ្ងៃនេះក្រុងប៉េកាំងនេះឯងហើយដែលចិញ្ចឹមប្អូន ។ នៅពេលរំលាយ «សមាគមមិត្តភាពខ្មែរ-ចិន» ប្អូនបានប្រកាសថា «រដ្ឋអធិបតេយ្យនៃសាធារណរដ្ឋប្រជាមានិតចិន ជំទាស់មិនឲ្យរដ្ឋអធិបតេយ្យខ្មែរមានសិទ្ធិជាម្ចាស់នៃខ្លួនឯង» ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយទៀតប្អូនបានបន្ថែមថា ប្រជាជាតិខ្មែរមិនត្រូវតំណាង ដោយពួក **ហ៊ូ យន់ ខៀវ សំផន ហ៊ូ នឹម តោគ ឆាយ** ។ល។ ដែលប្រទេសចិនបានទទួលស្គាល់ដោយរំលងលើក្បាលរដ្ឋាភិបាលនិងរដ្ឋខ្មែរថា មានតែពួកនេះទេដែលជាតំណាងត្រឹមត្រូវរបស់ប្រជារាស្ត្រខ្មែរ» ។

នៅក្នុងសារមួយ ផ្សាយតាមវិទ្យុជាតិនៅថ្ងៃ ៥ ខែតុលា ១៩៦៧ ប្អូនបានបរិហារជាថ្មីដល់ពួក **ហ៊ូ យន់ ខៀវ សំផន ចៅ សេង គោគ ឆាយ ហ៊ូ នឹម** មានសេចក្ដីថា ពួកនេះ «គោរងតែដឹងថា ខ្ញុំ-**សីហនុ** ត្រៀមខ្លួនចាំតទល់ជាមួយនឹងពួកនេះជានិច្ច ហើយខ្ញុំ-**សីហនុ** នឹងប្រយុទ្ធដោយគ្មានត្រាប្រណីរហូតដល់ចុងចប់ គឺរហូតដល់បំផ្លាញពួកមិនមែនខ្មែរឲ្យទាល់តែអស់ ទោះបីខ្ញុំ-**សីហនុ** ត្រូវគេបកស្បែកក៏ដោយ» ។

នៅ ខែមករា ១៩៦៨ ក្នុងឱកាសសន្និសិទសារពត៌មានមួយ ប្អូនបានបរិហារចំពោះអំពើវិទ្ធង្សនារបស់ចិនក្រហមដោយប្រកាសថា «ពួកខ្មែរក្រហម . . . បានសម្រេចថា ឈប់ធ្វើឲ្យមានសន្តិភាពនៅស្រុកខ្មែរ . . . ដែលប្រជារាស្ត្របានក្រេបជញ្ជក់អស់រយៈពេលច្រើនឆ្នាំមកហើយ . . ពួកនេះបានទទួលគ្រឿងសាស្ត្រាវុធ គ្រាប់រំសេវ ថ្នាំពេទ្យ និង សៀវភៅឃោសនាបោះពុម្ពនៅប្រទេសចិន ហើយដែលមានបដិរូបលោកប្រធាន **ម៉ៅ សេទុង** តាមព្រំប្រទល់ដែនខ្មែរ-ថៃ»។

ទ្រង់ប្អូន !

បងអាចបន្ថែមនូវសេចក្ដីដកស្រង់បែបនេះបានជាច្រើនថែមទៀត ត្បិតអីចាប់ពីឆ្នាំ ១៩៦៦ ដល់ឆ្នាំ ១៩៦៩ សេចក្ដីថ្លែងការណ៍របស់ប្អូនទាំងប៉ុន្មានត្រូវបានចងក្រងទុកនៅឯក្រសួងឃោសនាការទាំងអស់ ។ ជាការពិតណាស់ ដើម្បីធ្វើឲ្យមានតុល្យភាព ប្អូនបានធ្វើការរិះគន់តិះដៀលដល់មហាអំណាចបស្ចឹមប្រទេស ជា

ពិសេស គឺសហរដ្ឋអាមេរិកហើយដែលសារពត៌មានទាំងក្នុងលោកបានលើកយកទៅផ្សាយ ។ ការដែលប្អូនបំភ័ន្តមតិអន្តរជាតិបែបនេះ ប្អូនស្មានដោយច្រឡំថាប្អូនឯងបានឈ្មោះថា «អ្នកជើងឯកខាងអព្យាក្រឹត» ។

ប៉ុន្តែផ្ទុយទៅវិញ ប្អូនបានលួចធ្វើការទាក់ទងយ៉ាង «ជិតស្និទ្ធ» ជាមួយវៀតណាមខាងជើង - វៀតកុង រហូតដល់ទៅអនុញ្ញាតឲ្យពួកនេះ តាំងមូលដ្ឋានទ័ព មន្ទីរពេទ្យ មជ្ឈមណ្ឌលហ្វឹកហ្វឺន មូលដ្ឋានផ្ទុកភស្តុភារ និង មជ្ឈមណ្ឌលរៀបចំកងទ័ព នៅក្នុងទឹកដីខ្មែរ សម្រាប់ធ្វើការវាយប្រហារទៅវៀតណាមខាងត្បូង ។ មូលដ្ឋានទ័ពទាំងអស់នោះ តាំងនៅតាមបណ្ដោយព្រំប្រទល់ដែនយើងភាគខាងកើត ចាប់ពីខេត្ត រតនគិរី រហូតដល់ដែនសមុទ្រ ។ ប្អូនអាចធ្វើសេចក្ដីសន្និដ្ឋានខ្លួនឯងបានថា នយោបាយបែបនេះ គឺមិនមែនជានយោបាយអព្យាក្រឹតឡើយ ហើយជានយោបាយមួយទាញប្រទេសខ្មែរឲ្យធ្លាក់ចូល ក្នុងសង្គ្រាមដូចសព្វថ្ងៃ ហើយដែលប្រជាជាតិខ្មែរពុំចង់បានទាល់តែសោះ ។

នៅពេលដែលពួកនេះត្រូវបាន ប្រជារាស្ត្រនៅតំបន់ដែលពួកវាកាន់កាប់ដោយខុសច្បាប់ ដោយមានការអនុញ្ញាតពីប្អូនតែម្នាក់ឯង វាយប្រហារ ហើយនៅពេលដែលរដ្ឋាភិបាលពេញលក្ខណៈច្បាប់របស់ខ្មែរ ធ្វើការបរិហារ ពួកយួនខាងជើង-វៀតកុងគ្មានធ្វើអ្វីក្រៅពីចាប់ផ្ដើមប្រព្រឹត្តអំពើឈ្លានពានដោយចេញមុខ និងយ៉ាងបច្ឆ័ក តាមពាក្យសុំរបស់ប្អូនដែលប្អូនបានធ្វើទៅក្រុង កំណុង កាលពីខែមីនា១៩៧០។

ហេតុដូច្នេះហើយបានជានៅពេល ចាប់ផ្ដើមអំពើឈ្លានពានដំបូង គឺ នៅថ្ងៃ ២៩ មីនា ១៩៧០ យើងបានស្គាល់ច្បាស់នូវកងឯកភាពយៀកណាមខាងជើង-យៀកកុងនៅក្នុងទឹកដីយើងមានដូចតទៅ :

**កងពលធំលេខ ១**

– កងវរសេនាធំលេខ ១០១ ដេ : មានគ្នា ២.០០០ នាក់ តាំងនៅអង្គរបុរី ក្នុងខេត្តតាកែវ ។

**កងពលធំលេខ ៥**

– កងវរសេនាធំលេខ ១៧៤-០៥ និងលេខ ២៧៥ មានគ្នាទាំងអស់ចំនួន ៥.០០០ នាក់ តាំងនៅស្នួលក្នុងខេត្តក្រចេះ ។

**កងពលធំលេខ ៧**

– កងវរសេនាធំលេខ ១៤១-១៦៥ និងលេខ ២០៩ : មានគ្នា ៦.២០០ នាក់តាំងនៅមេមត់ក្នុងខេត្តកំពង់ចាម ។

**កងពលធំលេខ ៩**

– កងវរសេនាធំលេខ ៩៥-សេ-២៧១ និង ២៧២ : មានគ្នា ៦.០០០ នាក់តាំងនៅជប់ក្នុងខេត្តកំពង់ចាម ។

ទណាសិទ្ធេ ~ ៣

— កងវរៈសេនាធំលេខ ២៤-២៨-៤០-៦៦-៩៥-០ : មានគ្នាទាំងអស់ ១០.៨០០ នាក់តាំងនៅរតនគីរី-បរកែវ ។

— បន្ថែមប៉ុស្តិបញ្ជាការ និង សេនាធិការ : មានគ្នា ១២.០០០ នាក់ ។

— ក្រុមបញ្ជូនភស្តុការ : មានគ្នា ២៣.០០០ នាក់ ។

បូករួមទាំងអស់ទៅ កងទ័ពយៀកណាមខាងជើង-យៀកកុងដែលតាំងនៅតាមបណ្តោយព្រំប្រទល់ដែនខ្មែរមានគ្នាទាំងអស់ចំនួន ៦៥.០០០ នាក់ ។

ទ្រង់ប្អូន !

មកដល់ឥឡូវនេះសង្គ្រាមឈ្លានពានមានរយៈពេលជិត ៤ ឆ្នាំហើយ ។ ធ្វើឲ្យប្រជារាស្ត្រខ្មែរស្លាប់រងទុក្ខវេទនា និងវិនាសកម្មយ៉ាងច្រើនរកទីបំផុតគ្មាន ឯសាធារណរដ្ឋខ្មែរវិញមានគ្រឹះមាំទាំដោយមានស្ថាប័ននានា ត្រឹមត្រូវតាមច្បាប់ទម្លាប់ទាំងអស់ ដូច្នេះបងសូមរំលឹកដល់ប្អូននៅពេលនេះដោយបងដកស្រង់នូវពាក្យសម្តីរបស់ប្អូនខ្លះដែលផ្សាយនៅក្នុងទស្សនាវដ្តី «ឡឺសង្គម» នៅ ខែកក្កដា ១៩៦៦ មានដូចតទៅនេះ :

«រាជ្យបល្ល័ង្គសុខចិត្តផ្តេរតំណែងទៅឲ្យសាធារណរដ្ឋ ដោយស្មោះស្ម័គ្រ ប្រសិនបើឆន្ទៈនៃប្រជាពលរដ្ឋប្រុស-ស្រីភាគច្រើនចង់បានសាធារណរដ្ឋនេះ» ។

«ហើយរាជ្យបល្ល័ង្គស្នើដល់ប្រជារាស្ត្រអ្នកសាធារណរដ្ឋនិយម ឲ្យធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជៀសវាងនូវការបង្ហូរឈាមខ្មែរក្នុងការដណ្ដើមយកសាធារណរដ្ឋ ។ របបរាជនិយមគ្មានបំណងនឹង «ក្រាញ» នៅក្នុងអំណាចឡើយ ប្រសិនបើរបបនេះត្រូវបានប្រជារាស្ត្រលែងទុកចិត្ត» ។

ទ្រង់ប្អូន !

ឥឡូវសង្គ្រាមឃ្លានពានបានធ្វើឲ្យឈាមខ្មែរអស់ច្រើនណាស់ហើយ ហើយប្រជារាស្ត្រខ្មែរភាគច្រើនដាច់ខាត បានសម្ដែងឆន្ទៈតាំងពីខែ មិនា ១៩៧០ មកថា ចង់បានរបបសាធារណរដ្ឋនិយម ។ បងសូមអំពាវនាវចំពោះប្អូនឲ្យជួយប្រជារាស្ត្រខ្មែរ បញ្ចប់សង្គ្រាមនេះផង ដ្បិតអីកម្លាំងនៃការប្រយុទ្ធគ្នាបានថយដាលំដាប់នៅវៀតណាមខាងត្បូង និងនៅលាវ ហើយ ៗ នេះជាប្រផ្នូលនៃការដោះស្រាយបញ្ហាដោយសន្តិវិធី ។

នៅពេលនេះទៀត បងសូមឲ្យប្អូនប្រកាន់យកនូវគំនិតសមហេតុសមផលនិងសមរម្យផង ហើយប្អូនខ្លួនឯងអាចដឹងជាងគេទាំងអស់ថា គឺប្អូនពិតជាមិនមែនជា «មេដឹកនាំ» នៃរបស់ដែលគេហៅថា «ការតស៊ូរបស់ប្រជាជាតិ» នោះឡើយ ដ្បិតអីការតស៊ូដែលប្អូនស្មានដោយខុសនោះ គឺគ្មានអ្វីក្រៅពីអំពើឈ្លានពានរបស់កងទ័ពវៀតណាមខាងជើង - វៀតកុងដោយមានការឃុបឃិតពីពួកខ្មែរក្រហមប្រហែលជា ២០.០០០ នាក់ ហើយពួកខ្មែរក្រហមនេះទៀតសោត ក៏មិនមែនជាមនុស្ស របស់ប្អូនទៀត ។

ម្យ៉ាងទៀតជាការមួយជាក់ស្តែងដែលពុំអាចប្រកែកបាន គឺប្អូនបានពឹងផ្អែកទាំងស្រុងទៅលើចិននិងយួនខាងជើង ដើម្បីសុំលុយយកមកចំណាយផ្ទាល់ខ្លួន និងសំរាប់របស់ដែលប្អូនហៅថា «រដ្ឋាភិបាល» របស់ប្អូននោះ ។

ការនេះពុំអាចធ្វើឲ្យប្អូនមានអព្យាក្រឹតជាដាច់ខាត ។ ហើយបើគ្មានពួកនេះទេ ប្អូនពុំអាចមានប្រាក់កាសក្នុងការធ្វើដំណើររបស់ប្អូន និង សមាជិក «រដ្ឋាភិបាល» ប្អូនដែលភាគច្រើនរស់ជាអចិន្ត្រៃយ៍នៅ ក្រុងប៉ារិស នៅអាល្ហេរិច ឬនៅក្រុងប៉េកាំង ដោយគ្មានក្តីសង្ឃឹមថា ខ្លួនអាចវិលត្រឡប់មកជាន់ដីខ្មែរវិញបានឡើយ ។

ទ្រង់ប្អូន ត្រូវប្អូនធ្វើខ្លួនឲ្យបានជាស្តេចអ្នកជាមួយរូបនឹងគេឡើង ។ ជាទីបញ្ចប់ប្អូនត្រូវតែទទួលស្គាល់នូវបរាជ័យរបស់ប្អូន ហើយប្អូន ត្រូវតែបោះបង់ការរស់នៅជាកញ្ចះបរទេស ដែលគ្មានគោលបំណងអ្វីក្រៅពីការឆ្លៀតប្រវញ្ចលើគំនិតសងសឹករបស់ប្អូន ដើម្បីបម្រើប្រយោជន៍ផ្ទាល់ខ្លួនរបស់គេតែប៉ុណ្ណោះ ។

ប្រសិនបើប្អូនព្រមធ្វើយ៉ាងនេះ នោះប្អូនបានបង្ហាញឲ្យពិភពលោកទាំងមូលឃើញនូវគំនិតស្រឡាញ់ជាតិដ៏បរិសុទ្ធរបស់ប្អូន ដោយប្អូនសុខចិត្តលះបង់នូវតណ្ហាផ្ទាល់ខ្លួនចោល ដូចដែលប្អូនធ្លាប់បានប្រកាស ឲ្យគេឯងដឹងឮច្រើនលើកច្រើនគ្រាមកហើយ ។ ប្អូនតោងដឹងថា គ្រួសាររបស់ប្អូនទាំងអស់នៅភ្នំពេញ រង់ចាំនូវកាយវិការដ៏មហាប្រសើរនេះពីប្អូន ។

ហត្ថលេខា ៖ ស៊ីសុវត្ថិ - សិរិមត: